ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ស្ថិតិ នៃការអនុវត្តថវិការដ្ឋ

## State Budget Execution - GFSM1986 or TOFE

## ក្នុងទម្រង់បោះពុម្ពផ្សាយ ប្រចាំខែកញ្ញា ឆ្នាំ២០២៤


| ល.រ | មាតិកា | ទំព័រ |
|---|---|---|
| ១ | សេចក្តីសង្ខេប | ១ |
| ២ | ក្រាហ្វិកនៃការអនុវត្តថវិការដ្ឋ | ២ |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855)23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

# ១.សេចក្តីសង្ខេប

**១.ការអនុវត្តថវិការដ្ឋ** ប្រចាំខែកញ្ញា ឆ្នាំ២០២៤ ក្នុងទម្រង់ GFSM1986 ឬ TOFE បានបង្ហាញថា ក្នុងខែកញ្ញា ឆ្នាំ២០២៤ នេះ ការអនុវត្តចំណូលសរុបថ្នាក់ជាតិ សម្រេចបាន ១ ៨៨០ ប៊ីលានរៀល ស្មើនឹង ៦,២៩% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ និងការអនុវត្តចំណាយសរុបថ្នាក់ជាតិ អនុវត្តបាន ២ ៩៣៥ ប៊ីលានរៀល ស្មើនឹង ៨,៥១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

**២.ការអនុវត្តចំណូលក្នុងប្រទេសសរុបថ្នាក់ជាតិ** ប្រចាំខែកញ្ញា សម្រេចបាន ១ ៨៨០ ប៊ីលានរៀល ស្មើនឹង ៦,២៩% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ដែលប្រហាក់ប្រហែលគ្នាទៅនឹងលទ្ធផលនៃការអនុវត្ត នៅក្នុងខែកញ្ញា ឆ្នាំ២០២៣ ដែរ។ ក្នុងនោះ ចំណូលសារពើពន្ធ ប្រចាំខែកញ្ញា សម្រេចបាន ១ ៦៥៨ ប៊ីលានរៀល ស្មើនឹង ៦,៤៤% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ និងចំណូលមិនមែនសារពើពន្ធ សម្រេចបាន ២១៧ ប៊ីលានរៀល ស្មើនឹង ៧,០៥% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

**៣.ការអនុវត្តចំណាយសរុបថ្នាក់ជាតិ** ប្រចាំខែកញ្ញា សម្រេចបាន ២ ៩៣៥ ប៊ីលានរៀល ស្មើនឹង ៨,៥១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤, កើនប្រមាណជា ២,២៩% ធៀបនឹងខែកញ្ញា ឆ្នាំ២០២៣។ ក្នុងនោះ ចំណាយចរន្ត ប្រចាំខែកញ្ញា សម្រេចបាន ១ ៣៩៨ ប៊ីលានរៀល ស្មើនឹង ៦,៧១% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤, ចំណាយមូលធន សម្រេចបាន ៧៦៤ ប៊ីលានរៀល ស្មើនឹង ៥,៤៩% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤។

**៤.ការប្រើប្រាស់ហិរញ្ញប្បទានថ្នាក់ជាតិ** ត្រូវបានបន្តពង្រឹងការគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងស្មារតីយកចិត្តទុកដាក់ខ្ពស់ ឆ្លើយតបទៅនឹងតម្រូវការចំណាយបានទាន់ពេលវេលា។ ជាក់ស្តែង ក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០២៤, ការអនុវត្តហិរញ្ញប្បទានពីបរទេស សម្រេចបាន ៤ ៨៨៣ ប៊ីលានរៀល ស្មើនឹង ៤២,៩៨% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ និងការអនុវត្តហិរញ្ញប្បទានក្នុងស្រុកសរុបថ្នាក់ជាតិ សម្រេចបាន ៣ ៣៣៣ ប៊ីលានរៀល ស្មើនឹង ៥៩,៨៨% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤, ស្របពេល ប្រាក់បញ្ញើរដ្ឋាភិបាល សរុបមានប្រមាណជា ៤៨ ប៊ីលានរៀល។

✲✲✲✲

# ក្រាហ្វិក នៃការអនុវត្តថវិការដ្ឋ

### ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០២៣-២០២៤




### ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ ២០២៣-២០២៤




### ចំណាយចរន្ត និង វិនិយោគ ឆ្នាំ ២០២៣-២០២៤




### ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០២៣-២០២៤




Source: MEF

### ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០២៣-២០២៤




### ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០២៣-២០២៤

